**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ...០៥៦/១៨...ក. ស. ភ.

ថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព. ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## មហាសន្និបាតភាគហ៊ុនិកលើកទី ៣ របស់កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" របស់ ក. ស. ភ. ទាំងអស់មេត្តាជ្រាបថា៖ យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក. ស. ភ. ក្នុងកិច្ចប្រជុំលើកទី១០ អាណត្តិទី៦ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ក. ស. ភ. នឹងរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៣ តាមការកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក (Record Date) : **ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨**

២. កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី៣ : **ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨**

៣.ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី៣: សាលប្រជុំជាន់ទី៣ នៃអគាររដ្ឋបាល ទីស្នាក់ការកណ្តាល (ចំណតផែថ្មី TS៣) ដែលស្ថិតនៅអគារលេខ ៦៤៧ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤. របៀបវារៈនៃមហាសន្និបាតភាគហ៊ុនិកលើកទី៣ រួមមាន៖

| | |
|---|---|
| ពីម៉ោង ៨:០០-៩:០០ | ចុះវត្តមានអ្នកចូលរួម |
| ពីម៉ោង ៩:០០-៩:៣០ | ប្រកាសហេតុ |
| ពីម៉ោង ៩:៣០-១០:៣០ | - មតិស្វាគមន៍របស់ប្រធានមហាសន្និបាត<br>- បទបង្ហាញស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅអនុវត្តការងារឆ្នាំ២០១៨<br>- សំណួរ-ចម្លើយ |
| ពីម៉ោង ១០:៣០ -១០:៤៥ | មតិបិទកម្មវិធី |

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី **ធានាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ក. ស. ភ.) ឬ អាចទទួលបានលិខិតអញ្ជើញនៅ



ទីស្នាក់ការកណ្តាល៖ អគារលេខ៦៤៩ តីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh

ទីស្នាក់ការកណ្តាលរបស់ ក. ស. ភ. ដែលមានអាសយដ្ឋាននៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅរៀងរាល់ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ខែមីនា ឆ្នាំ២០១៨។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកមេត្តាទៅបញ្ជាក់ពីការចូលរួមនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណវិនិយោគិន និងអត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែន ចាប់ពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨ នៅរៀងរាល់ថ្ងៃធ្វើការ។

❖ **បញ្ជាក់** ÷ ភាគហ៊ុនិកដែលអញ្ជើញមកចូលរួមមហាសន្និបាតភាគហ៊ុនិក សូមយកមកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់ជូន/ផ្ញើជូន ដើម្បីចុះវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៣ របស់ ក. ស. ភ.។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក ធនាគារ អេស៊ីលីដា ភីអិលស៊ី និងកំពង់ផែស្វយ័តភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនង ដូចខាងក្រោម÷

**១.ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋានៈជាន់ទី៥អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ : (៨៥៥) ២៣ ៩៩៨ ៧៧៧ (Ext : ៨៣១៦៧)
- ទូរសារ : (៨៥៥) ២៣ ៩៩៨ ៦៦៦
- ទូរសព្ទដៃ : (៨៥៥) ១៥ ៦០០ ៧៤៣ (Ext : ០៥០១៣)
  (៨៥៥) ១៥ ៩០០ ៥៣៨ (Ext : ០៥០២០)
  (៨៥៥) ៦១ ២៨៧ ៧៦៦ (Ext :០៥០២០)
- សារអេឡិចត្រូនិក : lim.an@acledabank.com.kh

**២.កំពង់ផែស្វយ័តភ្នំពេញ**

- អាសយដ្ឋានអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទដៃ៖ ០១០ ៨៤៤ ៣៦៧ /០១០ ៨៤៤ ៣៧៥ /០១០ ៨៤៤ ០១៧
- អ៊ីម៉ែល ៖ ppapmpwt@online.com.kh

**ជ.គណៈកម្មការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី ៣**

**ប្រធាន**

**ហ៊ី-បាវី**

**ចម្លងជូន÷**
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក)
-សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.
-សវនករផ្ទៃក្នុងរបស់ ក. ស. ភ.
-សវនករឯករាជ្យរបស់ ក. ស. ភ.
- ក្រុមហ៊ុន KPMG
*"ដើម្បីជូនជ្រាប"*
-ធនាគារ អេស៊ីលីដា ភីអិលស៊ី
(ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់)
*"ដើម្បីសហការផ្សព្វផ្សាយ"*
-ឯកសារ-កាលប្បវត្តិ